ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

# អនុសារណៈយោគយល់
# ស្ដីអំពីការអនុវត្តន៍គំរោងកែលំអ
# ប្រព័ន្ធធារាសាស្ត្រ៥កុម្ភៈ

# Memorendum of Understanding
# for the Improvement of
# 5 Kumpheak Irrigation Scheme

ថ្ងៃទី២៣ ខែមេសា ២០១០

**23 April 2010**

## អនុសារណៈយោគយល់
## ស្តីអំពីការអនុវត្តន៍គំរោងកែលំអប្រព័ន្ធធារាសាស្ត្រ៥កុម្ភៈ
## ឃុំល្វាលើ ស្រុកចំការលើ ខេត្តកំពង់ចាម

# Memorendum of Understanding (MoU)
# for the Improvement of 5 Kompheak Irrigation Scheme
# in Lvea Leu Commune, Chamkar Leu district, Kompong Cham province

**រវាង /*Between***

**អង្គការហ្គ្រេត**
ដែលហៅកាត់ថា "GRET" តំណាងដោយលោក **Mr. Cédric Salze** តំណាងអង្គការប្រចាំប្រទេសកម្ពុជា។

**GRET** international organization,
hereafter called "GRET" represented by **Mr. Cédric Salze,** Gret representative in Cambodia.

**និង /*And***

**សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រ៥កុម្ភៈ**
តំណាងដោយលោក **ញឹម សុភាព** ប្រធាន ស.ក.ប.ទ. ប្រព័ន្ធធារាសាស្ត្រ៥កុម្ភៈ មានទីតាំង នៅឃុំល្វាលើ ស្រុកចំការលើ ខេត្តកំពង់ចាម។

**The Farmer Water User Community of '5 Kompheak'**,
hereafter called "the FWUC", represented by **Mr. Nheum Sopheap,** FWUC president, located in Chamkar Leu district, Kompong Cham province.

**និង /*And***

**ឃុំ ល្វាលើ**
តំណាងដោយ លោក **ឡឹក ប៊ុនសែ** ជន្ទុកទី២ឃុំ ល្វាលើ ស្រុកចំការលើ ខេត្តកំពង់ចាម។

**The commune of Lvea Leu,**
represented by **Mr. Lek Bunse,** second vice-chief of Lvea Leu commune, located in the Chamkar Leu district, Kompong Cham province.

## បានឃើញ / *having seen*

- កិច្ចព្រមព្រៀងឧបត្ថមថវិកាដោយទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ សំរាប់គំរោងអ៊ីរ៉ាម( លេខ CZ1324.01.X) ចុះហត្ថលេខានៅថ្ងៃទី១៩ ធ្នូ ២០០៨សំរាប់ គំរោងអាស៊ីរី
- កិច្ចព្រមព្រៀងជាក្រុមរវាង IRAM, AVSF និង GRET ចុះហត្ថលេខានៅថ្ងៃទី១៧ មករា ២០០៩ សំរាប់ការអនុវត្តន៍គំរោងអាស៊ីរី
- កិច្ចសន្យាជំនួយរវាងសហគមន៍អ៊ឺរុប និងហ្គ្រេត(ref. DCI-FOOD/2009/213-720) ចុះហត្ថលេខានៅថ្ងៃទី២៣ ធ្នូ ២០០៩
- កិច្ចសន្យាផ្តល់សេវាកម្មវគ្គ២ រវាងស.ក.ប.ទ ៥កុម្ភៈ និងមជ្ឈមណ្ឌលសេវាកម្ម ធារាសាស្រ្ត សំរាប់ការគាំទ្រផ្នែកបច្ចេកទេស ចុះហត្ថលេខានៅថ្ងៃទី២២ មេសា ២០១០។

- The Funding Agreement from AFD to IRAM (ref. CZ1324.01.X) signed on 19/12/2008 for ASIrri project
- The Grouping Agreement between IRAM, AVSF and GRET signed on 17/01/2009 for ASIrri project implementation
- The Subsidy Contract between European Union and GRET (ref. DCI-FOOD/2009/213-720) signed on 23/12/2009 for the project named: "Development of food production, farming incomes, nutrition and resilience in rural Cambodia"
- The service contract No.2 between FWUC of 5 Kumpheak and the Irrigation Service Centre for technical support signed on 22 April 2010.

### ភាគីទាំងអស់បានព្រមព្រៀងគ្នាដូចតទៅ:

### *The parties have agreed that:*

## មាត្រា ១: គោលបំណងនៃអនុស្សារណៈយោគយល់

## Article 1: Objective of the Memorendum of Understanding (MoU)

អង្គការហ្គ្រេតតាមរយៈគំរោង អាស៊ីរី ឧបត្ថមថវិកាដោយទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ និង សហគមន៍អ៊ឺរុប នឹងប្រគល់សិទ្ធជាម្ចាស់គំរោងអោយ ស.ក.ប.ទ. ប្រពន្ធ័ធារាសាស្រ្ត៥កុម្ភៈ ដែលជាផ្នែកមួយនៃថវិកាវិនិយោគ របស់គំរោងអាស៊ីរីសំរាប់ធ្វើការសាងសង់ និងជួសជុលសំណង់ធារាសាស្រ្ត ៥កន្លែង នៅក្នុងប្រពន្ធ័ធារាសាស្រ្ត ៥កុម្ភៈ ដែលមានទីតាំង ស្ថិតក្នុង ឃុំ ល្វាលើ ស្រុកចំការលើ ខេត្តកំពង់ចាមមានដូចខាងក្រោម។ យោងតាមគំរោង អនុញ្ញាតិអោយជួសជុលឡើងវិញចេញថ្ងៃទី៤ ខែមិនា ឆ្នាំ២០១០ របស់មន្ទីធនធានទឹក និងឧតុនិយម ខេត្តកំពង់ចាម បានឃើញ និងសំរេចដាក់អោយធ្វើការកែលំអប្រពន្ធ័ធារាសាស្រ្ត៥កុម្ភៈ ឡើងវិញ មានដូច ខាងក្រោម:

១. សាងសង់សំណង់លូមានទ្វារ១កន្លែង
២. សាងសង់សំណង់ស្ពាក់ទឹក១កន្លែង
៣. ជួសជុលសំណង់បែងចែកទឹកមានទ្វា៣ចំនួន១កន្លែង
៤. ជួសជុលសំណង់ទ្វារទឹកភូមិបីចំនួន១កន្លែង
៥. សាងសង់សំណង់ការពារការហូរច្រោះមុខទ្វារទឹកចំនួន១កន្លែង

អង្គការ ហ្គ្រេត តាមរយៈគំរោង***អាសុីរី*** អាជ្ញាធរឃុំល្វាលើ និងស.ក.ប.ទ. ប្រពន្ធ័ធារាសាស្រ្ត៥កុម្ភៈ នឹងធ្វើការសហការអោយអស់ពីលទ្ធភាព ធ្វើយ៉ាងណាអោយសំរេចបាននូវការអនុវត្តន៍គំរោងខាងលើនេះ ដោយយោងតាមអនុស្សរណៈយោគយល់នេះ។

GRET through its project named 'ASIrri' funded by AFD and EU will delegate its position of contracting owner to the FWUC concerning a part of the ASIrri investment funds in order to construct and repair 5 infrastructures within the 5 February scheme in Lvea Leu commune, Chamkar Leu district, Kompong Cham Province, such as:

1. construct one new pipe structure
2. construct one new check structure
3. repair one water gate (3 gates)
4. repair one water gate
5. construct one stone wall protection

as described in the document "Project of rehabilitation of the irrigation scheme in Lvea Leu Commune, Chamkar Leu District, Kompong Cham Province" realized and signed by the PDoWRaM of Kompong Cham and dated on 4 March 2010.

GRET ASIrri project, Lvea Leu Commune and 5 February FWUC will closely collaborate together for the implementation of this project according to the provisions within this MoU.

## មាត្រា ២: រយៈពេល

## Article 2: Duration

អនុស្សរណៈយោគយល់នេះមានរយៈពេល <u>៨ខែ</u> (រយៈពេលសាងសង់២ខែ និងដាក់ឱ្យដំណើរការ៦ខែ) ដែលចូលជាធរមានចាប់ ពីថ្ងៃចុះហត្ថលេខានេះតទៅ។

This MoU duration is **<u>8 months</u>** (duration of construction -2 months and starting operation period – 6 months)). It comes into force from the date of its signature.

## មាត្រា ៣: ភារកិច្ចនៃដៃគូ

## Article 3: Obligation of the parties

**អង្គការ GRET នឹង**

- ផ្តល់ជូនថវិកាឧបត្ថម្ភដែលមានទឹកប្រាក់ជាអតិបរិមាចំនួន ***២៣២២០.៩០ ដុល្លារ*** (*ពីរម៉ឺនបីពាន់ពីររយម្ភៃ និងកៅសិបដុល្លាអាមេរិច*) ដើម្បីវិនិយោគលើការកែលំអប្រពន្ធ័ធារាសាស្រ្ត៥កុម្ភៈ *ដូចមានចែងក្នុងមាត្រា១*។

- ចូលរួមរៀបចំរាល់ឯកសារទាំងអស់ដែលមានពាក់ពន្ធ័នឹងកិច្ចសន្យា

- ចូលរួមដេញថ្លៃ និងជ្រើសរើសអ្នកទទួលការសាងសង់ប្រកបដោយតម្លាភាព និងយុត្តិធម៌ និងដោយយោងតាមនិតិវិធីរបស់ ទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ និង សហគមន៍អ៊ឺរុប។

**GRET will:**

- Pay the construction and rehabilitation works of 5 Kompheak scheme described in the Article 1 up to ***23,220.90 US$*** (*Twenty three thousand two hundred twenty US dollars ninety cents*)
- Participate in the preparation of all documents and related contracts.
- Participate in bidding and selection of work contractors in a transparent and fair way and in accordance with EU and AFD markets procedures.

**ឃុំ ល្វាលើ នឹង:**

- ជួយ ស.ក.ប.ទ. ក្នុងការអនុវត្តន៍រាល់សកម្មភាពការងារនានាដែលពាក់ពន្ធ័និងគំរោងរួមមាន:
    - ចូលរួមនៅក្នុងការរៀបចំឯកសារនានាព្រមទាំងកិច្ចសន្យាទាំងឡាយ ដែលពាក់ពន្ធ័។
    - ចូលរួមក្នុងការដេញថ្លៃ និងជ្រើសរើសអ្នកទទួលការសាងសង់ ដោយយោងតាមនិតិវិធីរបស់ទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ និងសហគមន៍អ៊ឺរុប
    - ប្រមូល និងផ្សព្វផ្សាយពត៌មានអោយដល់អាជ្ញាធរស្រុក ខេត្ត និងភូមិពាកពន្ធ័
    - ត្រួតពិនិត្យ និងសំរបសំរួលការងារសាងសង់ដែលធ្វើឡើងដោយអ្នកទទួលការសាងសង់។
- សំរេច និងអនុមត័យកថវិកាមូលនិធិឃុំឆ្នាំ ២០១១ ដែលមានទឹកប្រាក់ចំនួន ៥០ ០០០ ០០០ រៀល (ហាសិបលានរៀល) ដើម្បីចូលរួមបន្តសាងសង់ និងថែទាំប្រពន្ធ័ធារាសាស្ត្រ ៥ កុម្ភៈ។

**The commune of Lvea Leu will:**

- assist the FWUC in activities related to project including:
    - Participate in the preparation of all documents and related contracts.
    - Participate in bidding and selection of work contractors in a transparent and fair way and in accordance with EU and AFD markets procedures.
    - Gather and disseminate information to other authorities at district, provincial and village levels
    - Control and facilitate the construction works implemented by the contractor.
- Decide and approve the use of commune investment funds (CIF) in the year 2011 being equal to 50.000.000 Riels for further construction and maintenance of the 5 Kompheak irrigation scheme.

**ស.ក.ប.ទ៥កុម្ភៈនឹង:**

- ជួយរៀបចំការដេញថ្លៃ និងជ្រើសរើសអ្នកទទួលការសាងសង់ ជាមួយមជ្ឈមណ្ឌលសេវាកម្ម ធារាសាស្ត្រ ប្រកបដោយតម្លាភាព និងយុត្តិធម៌ដោយយោងតាមនិតិវិធីរបស់ទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ និង សហគមន៍ អ៊ឺរុប។
- ត្រួតពិនិត្យ និងសំរបសំរួលការងារសាងសង់ដែលធ្វើឡើងដោយអ្នកទទួលការសាងសង់ ជាមួយ មជ្ឈមណ្ឌល សេវាកម្មធារាសាស្ត្រ។
- អនុមត័របាយការណ៍របស់ក្រុមបច្ចេកទេស និងអ្នកទទួលការសាងសង់ និងដាក់សំណើជូន អង្គការហ្គ្រេតនូវសំណើបង់ប្រាក់របស់អ្នកទទួលការសាងសង់។

- ប្រមូល និងផ្សព្វផ្សាយពត៌មានដល់សមាជិក និងធានាថាសមាជិកទាំងអស់ យល់ព្រមធ្វើការសាងសង់ និងឯកភាពលើផែនការសាងសង់។

**The FWUC will:**

- Organize the bidding and selection of work contractors together with the technical support of the ISC team in a transparent and fair way and in accordance with EU and AFD market procedures
- Control and facilitate the construction works done by the contractor with the technical support of the ISC team.
- Validate and receive the construction works made by the contractor and request the payment from GRET to the contractor.
- Gather and disseminate information to its members and ensure that the FWUC members have agreed to these construction works and planning.

## មាត្រា ៤: ការដេញថ្លៃ ធ្វើកិច្ចសន្យា និងការតាមដានការងារសាងសង់

## Article 4: Bidding, contracting and monitoring

- **ការដេញថ្លៃលើហេដ្ឋារចនាសម្ព័ន្ធ:**
  មានឯកសារដេញថ្លៃចំនួន ១ច្បាប់គត់ និងនិតិវិធីនៃការដេញថ្លៃតែមួយគត់សំរាប់ការដាក់អោយដំណើរការដេញថ្លៃគំរោងកែលំអប្រពន្ធ័ធារាសាស្រ្ត៥កុម្ភៈនេះ។

- **ការធ្វើកិច្ចសន្យាលើហេដ្ឋារចនាសម្ព័ន្ធ**
  មានតែអ្នកទទួលការតែម្នាក់គត់ដែលនឹងត្រូវបានជ្រើសរើសតាមរយៈការដេញថ្លៃ ដែលប្រកបដោយ តម្លាភាព និងយុត្តិធម៌ និងដោយយោងតាមនិតិវិធីរបស់ទីភ្នាក់ងារ បារាំងសំរាប់ការអភិវឌ្ឍន៍ និង សហគមន៍អ៊ឺរុប។ អ្នកទទួលការសាងសង់ត្រូវតែមានលក្ខណៈសម្បត្តិតាមសៀវភៅណែនាំពិសេសស្តីពីការអនុវត្តន៍គំរោងកែលំអប្រពន្ធ័ធារាសាស្រ្ត៥កុម្ភៈ និងមានកិច្ចសន្យាតែ១ ប៉ុណ្ណោះ ផងដែរ។

- **តាមដានការងារសាងសង់**
  រាល់ការតាមដានការរីកចំរើនការងារសាងសង់នឹងត្រូវធ្វើឡើងដោយក្រុមបច្ចេកទេសដែលរួមមាន តំណាងម្នាក់មកពីស្ថាប័ននិមួយៗរួមមាន ស.ក.ប.ទ. ឃុំ និង អង្គការ ហ្គ្រេត ។ វិស្វកររបស់មជ្ឈមណ្ឌលសេវាកម្មធារាសាស្រ្ត ជាតំណាងអោយអង្គការហ្គ្រេតសំរាប់ការតាមដានការអារសាងសង់នេះ ។ នៅពេលដែលអ្នកទទួលការស៊ុំធ្វើការទូរទាត់ ការតាមដាន ត្រូវមានវត្តមានក្រុមបច្ចេកទេស អ្នកទទួលការសាងសង់ និងប្រធានការដ្ឋានរបស់គាត់គឺជាការចាំបាច់។

- **Bidding for infrastructure construction:**
  There will be one bidding document and one bidding process for the 5 infrastructures.

- **Contracting for infrastructure construction:**
  Only one contractor will be selected through a tendering process organized in a transparent and fair way and in accordance with EU and AFD market procedures. The winner must fulfill the requirements of the bidding documents. There will be only one contract.

- **Work Monitoring :**
  The contractor's work monitoring will be implemented by a supervising team composed of 1 representative of each institution, namely Commune, FWUC and GRET. The ISC

engineer will represent GRET for work monitoring. When a control will lead to payment under contract procedure, presence of all team and contractor and his work manager is compulsory.

## មាត្រា ៥: នីតិវិធីនៃការទូទាត់

## Article 5 : Payment procedures

ថវិកាឧបត្ថម្ភដែលផ្តល់ជូនដោយ គំរោងអាស៊ីរ៉ សំរាប់យកមកអនុវត្តគំរោងកែលំអនេះ នឹងត្រូវបានផ្តល់ជូន ដូចតទៅ:

- ស.ក.ប.ទ. នឹងស្នើដល់អង្គការហ្គ្រេត ឱ្យផ្ទេរសាច់ប្រាក់ ដល់អ្នកទទួលការ។ ការផ្ទេរនឹងត្រូវបានអនុម័ត ដោយអង្គការហ្គ្រេត ប្រសិនមានភ្ជាប់ជាមួយនូវរបាយកាណ៍ស្តីពីភាគរយការងារ ដែលអ្នកទទួលការសំរេចបាន និងមានចុះហត្ថលេខាបញ្ជាក់ពី ស.ក.ប.ទ. ៥កុម្ភៈ និងក្រុមអ្នកត្រួតពិនិត្យបច្ចេកទេសប្រចាំការដ្ឋាន។

- ចំនួនទឹកប្រាក់ឧបត្ថម្ភនេះនឹងត្រូវបានផ្តល់ជូន ជា៤តំណាក់កាល ទៅដំណាក់កាលនៃការទូរទាត់ប្រាក់ ដល់អ្នកទទួលការ។

| | | | |
|---|---|---|---|
| ▪ ២០ ភាគរយ | នៅពេលអ្នកទទួលការដឹកសំភារៈដល់ការដ្ឋាន | ស្មើនឹង ៤៦៤៤.៩ ដុល្លាអាមេរិច | |
| ▪ ៣០ ភាគរយ | នៅពេលការងារសំរេចបាន៥០ភាគរយ | | ស្មើនឹង ៦៩៦៦.០ ដុល្លាអាមេរិច |
| ▪ ៤០ ភាគរយ | នៅពេលការងារសំរេចបាន១០០ភាគរយ | | ស្មើនឹង ៩២៨៨.០ ដុល្លាអាមេរិច |
| ▪ ១០ ភាគរយ | សំរាប់ការធានាគុណភាពសំណង់រយៈពេល៦ខែ | | ស្មើនឹង ២៣២២.០ ដុល្លាអាមេរិច |

- ការទូរទាត់ថវិកាសំរាប់៣វគ្គដំបូងនឹងត្រូវធ្វើទៅតាមការបង្វែរសាច់ប្រាក់ពីគណនីរបស់អង្គការហ្គ្រេត ទៅចូលក្នុងគណនីរបស់អ្នកទទួលការ ដោយភ្ជាប់មកជាមួយលិខិតបញ្ជាក់នៃការរីកចំរើនការងារសាងសង់ ចុះហត្ថលេខា ដោយភាគី ពាក់ពន្ធ័ដែលបានបញ្ជាក់អំពីការដល់តំណាក់កាលនៃការទូរទាត់។

ឯកសារធានាគាររបស់អ្នកទទួលការសងសង់រួមមាន:

| |
|---|
| ឈ្មោះអ្នកទទួលការសាងសង់: |
| ឈ្មោះម្ចាស់គណនីធានាគា: |
| ឈ្មោះធានាគា និងអាស័យដ្ឋាន: |
| លេខគណនីធានាគា: |

- ទឹកប្រាក់ចំនួន១០ ភាគរយ សំរាប់ការធានាគុណភាពសំណង់រយៈពេល៦ខែ ហ្គ្រេតនឹងធ្វើការ ផ្ទេរទៅអោយ គណនី ស.ក.ប.ទ ៥កុម្ភៈតាមរយៈឯកសារធានាគាដូចខាងក្រោម។ ស.ក.ប.ទ ៥កុម្ភៈនឹងទទួលខុសត្រូវចំពោះ ការទូទាត់ប្រាក់ធានានេះដោយខ្លួនឯងបន្ទាប់ពីយល់ឃើញថាការងារសាងសង់នេះត្រូវបានបញ្ចប់ និងអាចទទួលយកបាន។

ឯកសារធនាគារបស់ស.ក.ប.ទ៥កុម្ភៈរួមមាន:

| |
|---|
| ឈ្មោះស.ក.ប.ទ ៥កុម្ភៈ: |
| ឈ្មោះម្ចាស់គណនីធនាគា: |
| ឈ្មោះធនាគា និងអាស័យដ្ឋាន: |
| លេខគណនីធនាគា: |

The investment fund from ASIrri project which will be used to finance the project infrastructures will be released as follows.

- The FWUC will request to GRET the execution of the payments to the contractor by submitting a detailed work monitoring report indicating the percentage of work done and signed by all members of the Supervising Team. The transfer will be approved by GRET if the appropriate stage of work has been approved by all parties in the work monitoring form.

- The payments will be delivered in 4 installments according to the phases of work construction as follows:

| | | | |
|---|---|---|---|
| ▪ | **20%** | **payment after the working site installation** | **= 4,644.9 US$** |
| ▪ | **30%** | **payment after 50% work completion** | **= 6,966.0 US$** |
| ▪ | **40%** | **payment after 100% work completion** | **= 9,288.0 US$** |
| ▪ | **10 %** | **guarantee 6 month after work completion** | **= 2,323.0 US$** |

- The disbursement of ASIrri investment funds for the three first installments will be made by bank wire directly from GRET to the contractor bank account following the references below:

  The Bank references of the Contractor:

| |
|---|
| Name of the Contractor: NGUON SAMNANG |
| Name of the bank account owner: NGUON SAMNANG |
| Bank name and address: CAMBODIAN PUBLIC BANK - KOMPONG CHAM |
| Bank account number: 060-02-30-00808-9 |

- For the last installment of 10% guarantee for six months at 100% completion of the work, GRET will wire the amount to the FWUC bank account according to the reference below. The FWUC will take in charge the payment of this amount to the contractor by itself six months after work completion and after a monitoring visit to the infrastructures.

  The Bank references of the FWUC:

| |
|---|
| Name of the FWUC and bank account owner: |
| Bank name and address: |
| Bank account number: |

## មាត្រា ៦: ជំលោះ ភាពមិនយល់ព្រម
## Article 6: Disputes, Disagreements

- ហត្ថលេខីលើអនុសារណៈនេះយល់ព្រមដោះស្រាយដោយការស្រុះស្រួលគ្នា នូវរាល់វិវាទដែលកើតមានឡើងក្នុងការអនុវត្តន៍អនុសារណៈយោគយល់នេះ ។
- ក្នុងករណីមិនអាចផ្សះផ្សាបាន ភាគីត្រូវស្នើទៅតុលាការខេត្តកំពង់ចាម ។
- The signers of the agreement herewith agree to endeavor to settle out of court any dispute that may arise in its enforcement.
- Should such mediation fail, recourse shall be taken with the provincial tribunal of Kompong Cham.

## មាត្រា ៧: ការចូលជាធរមាននៃអនុសារណៈយោគយល់
## Article 7: Original copy and MoU validity

- អនុសារណៈយោគយល់នេះត្រូវបានធ្វើឡើងជា ៣ច្បាប់ ជាភាសាខ្មែរ និងអង់គ្លេស សំរាប់ភាគីនិមួយៗ។
- អនុសារណៈយោគយល់នេះចូលជាធរមានចាប់ពីពេលត្រូវបានចុះហត្ថលេខាដោយភាគីហត្ថលេខី។
- This MoU has been made in 3 original copies in both languages Khmer and English for each party.
- This MoU comes into force after its signature

**ធ្វើនៅ ល្វាលើ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១០**
**Made in Lvea Leu, on April, 23 2010**

**បានឃើញ និងឯកភាព**
**Seen and approved**

| តំណាង GRET<br>GRET Representative | មេឃុំល្វាលើ<br>Lvea Leu Commune chief | តំណាង ស.ក.ប.ទ.<br>FWUC Representative |
|---|---|---|
| | | |